រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

034KH01A-01

ការថ្វាយបង្គំព្រះជាម្ចាស់ដ៏ខ្ពស់បំផុត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៣៤

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

សូមទូលសូមអោយព្រះជាម្ចាស់ជួយរៀបចំអ្នក តាមរយៈការសិក្សាមេរៀននេះ អោយចេះដឹកនាំក្រុមជំនុំរបស់អ្នកអោយចេះថ្វាយបង្គំយ៉ាងពិតប្រាកដ ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងសរសើរតម្កើងព្រះអង្គទៀតផង ។

តើការថ្វាយបង្គំជាអ្វី ?

ការថ្វាយបង្គំព្រះជាម្ចាស់ដោយសេចក្តីពិត (យ៉ូហាន ៤:២៣) មានច្រើនផ្នែក ។ ដំបូង យើងត្រូវថ្វាយជីវិតរបស់យើងជាយញ្ញបូជាសិន គឺប្តេជ្ញាចិត្តស្រឡាញ់ព្រះជាម្ចាស់ និងមនុស្សឯទៀត ហើយប្តេជ្ញាចិត្តរស់ដោយបរិសុទ្ធ (រ៉ូម ១២:១) ។ បើសិនជាយើងគ្រាន់តែប្រើពាក្យសំដីសរសើរតម្កើង ប៉ុន្តែ ជីវិតយើងមិនបរិសុទ្ធ នោះយើងបន្ថោកព្រះនាមរបស់ព្រះជាម្ចាស់ហើយ (ម៉ាកុស ៧:៦) ។

ក្រៅពីការថ្វាយជីវិត ការសរសើរតម្កើងជាផ្នែកមួយទៀតនៃការថ្វាយបង្គំ ។ យើងសរសើរតម្កើង និងអរព្រះគុណព្រះជាម្ចាស់ចំពោះចរិតលក្ខណៈរបស់ព្រះអង្គ ដូចតទៅ : ព្រះហឫទ័យមេត្តាករុណា ព្រះហឫទ័យស្មោះស្ម័គ្រ ភាពថ្កុំថ្កើងឧត្តុងឧត្តម សេចក្តីស្រឡាញ់ដ៏ធំធេង ប្រាជ្ញាខ្ពស់បំផុត និងឫទ្ធានុភាពគ្មានព្រំដែន

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានយ៉ាងខ្លាំងក្លា ទូលសូមឱ្យព្រះជាម្ចាស់ប្រទានព្រះពរដល់ការថ្វាយបង្គំរបស់ក្រុមជំនុំ និងប្រទានឱ្យការថ្វាយបង្គំរបស់ក្រុមជំនុំមានឫទ្ធានុភាព ។
- រៀបចំគំរោងកម្មវិធីថ្វាយបង្គំអោយបានត្រឹមត្រូវ មុនពេលកំណត់ ជាមួយអ្នកដឹកនាំឯទៀត ។
- បង្រៀនក្រុមជំនុំ ឬ ក្រុមតូចរបស់អ្នកអំពីខ្លឹមសាររបស់ការថ្វាយបង្គំ ដើម្បីឱ្យពួកគេអាចថ្វាយព្រះពរ និងសរីរុងរឿងដល់ព្រះជាម្ចាស់ មិនមែនគ្រាន់តែចូលរួម ដើម្បីទទួលព្រះពរសំរាប់តែខ្លួនឯងប៉ុណ្ណោះទេ ។
- ដឹកនាំការថ្វាយបង្គំ (ឬជួយដឹកនាំផ្នែកទាំងឡាយរបស់កម្មវិធីថ្វាយបង្គំ ដោយប្តូរវេនគ្នាជាមួយអ្នកឯទៀត) ។
- ជួយក្រុមជំនុំទាំងមូលអោយអាចចូលរួម យោងទៅតាមអំណោយទានរបស់ពួកគេ ដូចជាការច្រៀង ការអធិស្ឋាន ការធ្វើទីបន្ទាល់ ការអានព្រះគម្ពីរ ការថ្លែងព្រះបន្ទូលដែលព្រះជាម្ចាស់បើកសំដែង ។ល។ ។

៧- តើអ្នកមានរៀបចំកម្មវិធីថ្វាយបង្គំពិសេស សំរាប់ថៃបុណ្យ ផ្សេងៗ ដូចជាពិធីអបអរព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញដែរឬទេ ? (កម្មវិធីថ្វាយបង្គំពិសេសខ្លះអាចជាការផ្សាយដំណឹងល្អ ព្រោះមានអញ្ជើញពួកអ្នកមិនទាន់ជឿអោយចូលរួម) ។

☐ មាន ។

☐ គ្មានទេ តែយើងនឹងធ្វើនៅពេលខាងមុខ ។

(ទំនុកតម្កើង ១០៨:១-៦) ។ លើសពីនេះទៅទៀត យើងសរសើរតម្កើងព្រះជាម្ចាស់ចំពោះកិច្ចការទាំងប៉ុន្មាន ដែលព្រះអង្គបានសំដែង ក្នុងចំណោមយើងរាល់គ្នា ។ យើងសរសើរតម្កើងព្រះអង្គ ព្រោះព្រះអង្គជាព្រះអាទិករ ដែលបង្កើតយើង ថែរក្សាយើងជាប់ជាប្រចាំ សង្គ្រោះយើងអោយរួចពីអំពើបាប តាមរយៈព្រះយេស៊ូ និងជួយយើងឱ្យបានរីកចំរើន ជាចាស់ទុំខាងព្រលឹងវិញ្ញាណតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ (ទំនុកតម្កើង ១១១:១-១០) ។

ព្រះវិញ្ញាណដ៏វិសុទ្ធ និងព្រះយេស៊ូមានតួនាទីសំខាន់ណាស់ ក្នុងការថ្វាយបង្គំរបស់យើង ។ ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយអ្នកជឿថ្វាយបង្គំ ដោយស្មោះស្ម័គ្រ និងដោយសេចក្តីពិត (យ៉ូហាន ៤:២៣) ។ ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងបានរួមជាមួយនឹងព្រះគ្រីស្ត ដែលគង់នៅស្ថានបរមសុខ ។ ពាក្យសរសើរតម្កើងរបស់យើងឡើងទៅដល់ព្រះជាម្ចាស់ជាព្រះបិតា តាមរយៈព្រះ-យេស៊ូគ្រីស្ត ដែលជាព្រះសិរសាខាងព្រលឹងវិញ្ញាណរបស់យើង (ហេប្រឺ ៤:១៤-១៦) ។



តើការប្រជុំថ្វាយបង្គំជាអ្វី ?

ការប្រជុំថ្វាយបង្គំ ជាឱកាសសំរាប់អោយពួកអ្នកជឿរួមចិត្តគ្នា ថ្វាយបង្គំព្រះជាម្ចាស់ ទុកព្រះអង្គជាព្រះអាទិករ ព្រះសង្គ្រោះ និង ព្រះអម្ចាស់ ។ ការដែលពួកអ្នកជឿច្រៀង អរព្រះគុណ និង សរសើរតម្កើងព្រះអម្ចាស់ជាមួយគ្នា បណ្តាលឱ្យមានបុទ្ធានុភាព និងមានភាពល្អអស្ចារ្យបំផុត ។ នៅពេលដែលពួកអ្នកជឿ ថ្វាយបង្គំដោយចិត្តគំនិតតែមួយ សំលេងតែមួយ និងជំនឿតែមួយ នោះព្រះជាម្ចាស់សព្វព្រះហឫទ័យខ្លាំងណាស់ (រ៉ូម ១៥:៥-៦) ។

ការប្រជុំថ្វាយបង្គំរួមមានការសរសើរតម្កើង ការអរព្រះគុណ ទំនុកតម្កើង បទភ្លេង បទចំរៀង ការលន់តួសារភាព ការ អធិស្ឋាន ការដាស់តឿនគ្នាទៅវិញទៅមក និងការធ្វើទីបន្ទាល់ (អេភេសូ ៥:១៨-២០) ។

នៅក្នុងកូឡូស ៣:១៦ យើងអាចឃើញចំណុចខ្លះនៃការថ្វាយបង្គំ : *«សូមព្រះបន្ទូលរបស់ព្រះគ្រីស្ត សណ្ឋិតនៅក្នុងបងប្អូនអោយបាន បរិបូណ៌ ។ ចូរប្រៀនប្រដៅ និងដាស់តឿនគ្នាទៅវិញទៅមក ដោយប្រាជ្ញាគ្រប់យ៉ាង ។ ចូរច្រៀងអរព្រះគុណព្រះជាម្ចាស់ក្នុង ចិត្ត ដោយប្រើទំនុកតម្កើង បទសរសើរ និងបទចំរៀងមកពីព្រះ វិញ្ញាណ »* ។

៤- តើអ្នកមានសុំអោយអ្នកផ្សេងទៀតជួយជីកនាំ និងមាន ភារៈកិច្ចក្នុងកម្មវិធីថ្វាយបង្គំដែរ ឬ មួយធ្វើអ្វីៗតែខ្លួនឯង ?

☐ មាន ។

☐ គ្មានទេ តែខ្ញុំនឹងចាប់ផ្តើមធ្វើ ។

៥- តើអ្នកកំណត់ពេលធ្វើពិធីកាច់នំបុ័ងដូចម្តេច ?

☐ រាល់អាទិត្យ ។

☐ មួយខែពីរដង ។

☐ រាល់ខែ ។

៦- តើអ្នកមានអធិស្ឋានសំរាប់សេចក្តីត្រូវការផ្សេងៗ ដែល ក្រុមជំនុំកំពុងជួបប្រទះដែរឬទេ ?

☐ មាន ។

☐ គ្មានទេ តែយើងនឹងចាប់ផ្តើម ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើពេលអ្នករៀបចំកម្មវិធីថ្វាយបង្គំ អ្នកមានអធិស្ឋានច្រើនលួមគ្រប់គ្រាន់ដែរឬទេ ?

☐ មាន ។

☐ គ្មានទេ តែខ្ញុំនឹងចាប់ផ្តើម ។

២- តើក្នុងក្រុមជំនុំរបស់អ្នក មានរបៀបដែលនាំអោយអ្នកចូលរួមអាចមើលឃើញ ឬ ស្គាល់ចំរៀងអោយបានគ្រប់គ្នា ដែរឬទេ ?

☐ មាន ។

☐ គ្មានទេ តែខ្ញុំនឹងចាប់ផ្តើមរៀបចំរបៀបមួយ ។

៣- តើអ្នកមានកត់ត្រាដំណើរការនៃកម្មវិធីថ្វាយបង្គំ និងបទចំរៀងត្រឹមត្រូវគ្រប់គ្រាន់មុនពេលកំណត់ ដើម្បីអោយពួកតន្ត្រីករ និងអ្នកដែលមានមុខនាទីពិសេសក្នុងកម្មវិធី អាចមកចូលរួម ដោយរៀបចំខ្លួនបានត្រឹមត្រូវឬទេ ?

☐ មាន ។

☐ គ្មាន តែខ្ញុំនឹងចាប់ផ្តើមធ្វើ ។

ការប្រជុំថ្វាយបង្គំច្រើនតែសំរាប់ពួកអ្នកជឿ ពីព្រោះអ្នកមិនទាន់ជឿមិនអាចថ្វាយបង្គំព្រះជាម្ចាស់តាមវិញ្ញាណ និងតាមសេចក្តីពិតបានទេ (យ៉ូហាន ៤:២៤) ។ អ្នកដឹកនាំខ្លះ ធ្វើកម្មវិធីពីរយ៉ាងច្រឡំគ្នា គឺពួកគេរៀបចំធ្វើកម្មវិធីថ្វាយបង្គំសំរាប់អ្នកមិនទាន់ជឿ ហើយរៀបចំកម្មវិធីផ្សាយដំណឹងល្អសំរាប់ពួកអ្នកជឿ ! ។

សូមអាន និង រិះគិតពិចារណាពីបទព្រះគម្ពីរ ១ កូរិនថូស ១៤:២៣-៤០ ។ នៅក្នុងខទាំងនេះ មានគោលការណ៍ណែនាំអំពីការថ្វាយបង្គំចំនួនប្រាំពីរ (គឺអំពីកិច្ចការដែលត្រូវធ្វើ កិច្ចការដែលមិនត្រូវធ្វើ និងរបៀបធ្វើកិច្ចការដែលត្រូវធ្វើ)។ ក្រុមត្រូវតួចលួមដើម្បីអាចយកគោលការណ៍ណែនាំទាំងនេះមកអនុវត្តបាន ។ សូមសរសេរគោលការណ៍ណែនាំទាំងប្រាំពីរនេះ នៅចន្លោះខាងក្រោមនេះ :

កម្មវិធីថ្វាយបង្គំ សំរាប់ :

☐ ពួកអ្នកជឿ ។

☐ មិត្តភក្តិដែលមិនទាន់ជឿ ។

កម្មវិធីផ្សាយដំណឹងល្អ សំរាប់ :

☐ ពួកអ្នកជឿ ។

☐ មិត្តភក្តិដែលមិនទាន់ជឿ ។

ការថ្វាយបង្គំ គឺសំរាប់ពួកអ្នកជឿ ឯការផ្សាយដំណឹងល្អវិញ គឺសំរាប់ពួកអ្នកដែលមិនទាន់ជឿ ។

មនុស្សមិនទាន់ជឿ មិនអាចចូលរួមថ្វាយបង្គំដោយចិត្តស្មោះស្ម័គ្រ និងដោយសេចក្តីពិតទេ ។ ព្រោះអ្វី ? (យ៉ូហាន ៤:១៩-២៤)។

គំរូអំពីកម្មវិធីថ្វាយបង្គំមួយ

(ដែលរៀបចំឡើង ដោយប្រើវិធីដែលមាននៅទំព័រមុន)

- អធិស្ឋានបើកកម្មវិធី និងច្រៀងទំនុកតម្កើង ១00
- អធិស្ឋានរៀងៗខ្លួន ទូលសូមអោយព្រះជាម្ចាស់អត់ទោស និងអាន ១ យ៉ូហាន ១:៩
- បទចំរៀងទីបន្ទាល់ (លេខ ១៦ ទំនុកខ្មែរ)
  ចំរៀងអរព្រះគុណ (លេខ ៤៦ ទំនុកខ្មែរ)
  ចំរៀងសរសើរតម្កើង (លេខ ០១)
  ចំរៀងថ្វាយបង្គំ (លេខ ០២)
- ការអានព្រះគម្ពីរ : ភីលីព ៣:១-២១ (លោកសុខា)
- ចំរៀងទាក់ទងអំពីសេចក្តីអធិប្បាយ (លេខ ១៥៣ ទំនុកខ្មែរ)
- សេចក្តីអធិប្បាយ (លោកគ្រូស្រ៊ីន)
- ការអធិស្ឋានសំរាប់ប្រទេសជាតិ សំរាប់ការផ្សាយដំណឹងល្អ និងសំរាប់អ្នកជំងឺ (លោកស្រីផល្លា)
- ការប្រកាសដំណឹងល្អ ឬកម្មវិធីផ្សេងៗ (លោកធឿន)
- ការដាក់ដង្វាយ (លោកស្រីគីមស្ង)
- ពិធីកាច់នំប៉័ង (លោកធឿន)
- ព្រះគ្រីស្តជាគ្រប់ទាំងអស់ដល់អ្នក (លេខ ១០៥ ទំនុកខ្មែរ)
- អធិស្ឋានទូលសូមព្រះពរនៅទីបញ្ចប់ (លោកគ្រូស្រ៊ីន)

© Project WorldReach © SEAN

ឧទាហរណ៍ ក្បែរការអានព្រះគម្ពីរ អ្នកអាចសរសេរថា« លោក សុខា» ជាអ្នកអាន ។ សូមទាក់ទងជាមួយអ្នកទាំងនោះ ហើយអធិស្ឋានជាមួយពួកគេ មុនកម្មវិធីថ្វាយបង្គំ ។ ត្រូវរៀបចំការហាត់ភ្លេង និងការច្រៀងសរសើរ ដើម្បីឱ្យស្គាល់សង្វាក់ ស្គាល់សំលេង និងស្គាល់ទំនុកជាមុន ។

៤- មកដល់ទីកន្លែងថ្វាយបង្គំអោយបានមុន ដើម្បីរៀបចំកន្លែងអោយមានសណ្តាប់ធ្នាប់ (កៅអី ព្រះគម្ពីរ សៀវភៅចំរៀង ថង់ដង្វាយ បញ្ជីសេចក្តីប្រកាស នំប៉័ង និងទឹកទំពាំងបាយជូរសំរាប់ធ្វើពិធីកាច់នំប៉័ង ហើយរឹតសំឡេងឧបករណ៍តន្ត្រីអោយបានត្រឹមត្រូវ ។ មនុស្សឯទៀតក៏ត្រូវជួយធ្វើកិច្ចការនេះដែរ) ។

៥- នៅក្នុងកម្មវិធីថ្វាយបង្គំ សូមទុកអោយព្រះវិញ្ញាណដ៏វិសុទ្ធណែនាំ នោះព្រះអង្គនឹងដឹកនាំកម្មវិធីថ្វាយបង្គំអោយប្រព្រឹត្តទៅតាមបែបបទ ដែលអ្នកគិតស្មានមិនដល់ ។ ត្រូវត្រៀមស្មារតីជានិច្ច ចាំទទួលធ្វើអ្វីៗ ដែលព្រះអង្គចង់អោយធ្វើ ។ ការថ្វាយបង្គំជាការជួបផ្តាល់ជាមួយព្រះជាម្ចាស់ ដែលមានព្រះជន្មរស់ ។

បើសិនជាការប្រជុំថ្វាយបង្គំទាំងអស់ សុទ្ធតែសំរាប់ពួកអ្នកជឿ នោះក្រុមជំនុំមិនរវល់យកចិត្តទុកដាក់គិតអំពីមនុស្សដែលត្រូវការស្គាល់ដឹងអំពីព្រះគ្រីស្តហើយ ។ ព្រោះអ្វី ?

_____

_____

_____

បើសិនជាការប្រជុំថ្វាយបង្គំទាំងអស់ សុទ្ធតែសំរាប់ពួកអ្នកមិនទាន់ជឿ នោះក្រុមជំនុំធ្វើអោយពួកអ្នកជឿទន់ខ្សោយហើយ ។ ព្រោះអ្វី ?

_____

_____

_____

តារាងនៅខាងក្រោមនេះប្រៀបធៀប «កម្មវិធីថ្វាយបង្គំ» និង «កម្មវិធីផ្សាយដំណឹងល្អ» ។ កម្មវិធីទាំងពីរនេះមានគោលបំណង មានអ្នកចូលរួម មានការអធិប្បាយ និងមានសកម្មភាពខុសប្លែកពីគ្នា ។

កម្មវិធីថ្វាយបង្គំ	កម្មវិធីផ្សាយដំណឹងល្អ
គោលបំណង : ថ្វាយបង្គំព្រះ-ជាម្ចាស់ ដែលយើងបានស្គាល់ហើយ ។	**គោលបំណង** : អំពាវនាវពួកអ្នកមិនទាន់ជឿ ឱ្យកែប្រែចិត្តគំនិត និងជឿលើព្រះយេស៊ូ ។
អ្នកចូលរួម : ពួកអ្នកជឿដែលកើតជាថ្មីហើយ (មិនមែនថាយើងមិនរាប់បញ្ចូលភ្ញៀវនោះទេ តែកម្មវិធីថ្វាយបង្គំជាប់ទាក់ទងនឹងអ្នកជឿខ្លាំងជាង) ។	**អ្នកចូលរួម** : ពួកអ្នកមិនទាន់ជឿ (ពួកគេស្តាប់ព្រះបន្ទូលដើម្បីឱ្យយល់ដឹងពីដំណឹងល្អ និងទទួលជឿ) ។
សេចក្តីអធិប្បាយ : ច្រើនតែទាក់ទងនឹងរបៀបរស់នៅ តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងការបំរើព្រះអង្គ និងមនុស្សឯទៀត ។	**សេចក្តីអធិប្បាយ** : ច្រើនតែទាក់ទងនឹងព្រះយេស៊ូ ដែលសុគត និងមានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះមនុស្សឱ្យរួចពីបាប ។
សកម្មភាព : ការអធិស្ឋាន ការអានព្រះគម្ពីរ ការច្រៀងសរសើរ ការធ្វើទីបន្ទាល់ ការដាក់ដង្វាយ និងការធ្វើពិធីកាច់នំប៉័ង ។	**សកម្មភាព** : គ្មានការដាក់ដង្វាយ គ្មានពិធីកាច់នំប៉័ង ។ អ្នកចូលរួម មិនសូវអធិស្ឋាន និង មិនសូវច្រៀងសរសើរតម្កើង ។

របៀបរៀបចំការថ្វាយបង្គំ

ខាងក្រោមនេះជារបៀបមួយដែលស្រួលអនុវត្ត :

១- អធិស្ឋាន ទូលសូមអោយព្រះជាម្ចាស់ដឹកនាំ និងចាក់ប្រេងតាំង (ប្រទានព្រះចេស្តា) មកលើអ្នកដែលចូលរួមថ្វាយបង្គំទាំងអស់ ។

២- នៅទំព័រ ទី ១៥ និង ទី ១៧ មានដាក់ជូនអំពីបញ្ជីផ្នែកសំខាន់ៗនៃកម្មវិធីថ្វាយបង្គំ ។ សូមយកក្រដាសមួយសន្លឹកមកកត់ត្រាចំណុចផ្សេងៗនៃកម្មវិធីថ្វាយបង្គំដូចជា : ចំរៀងដែលត្រូវច្រៀង វគ្គព្រះគម្ពីរដែលត្រូវអានជាដើម ។ កិច្ចការទាំងអស់នេះ ត្រូវសរសេរតាមលំដាប់លំដោយដែលត្រូវធ្វើតាម ពេលថ្វាយង្គំ ។

៣- សូមគិតអំពីផ្នែកណាខ្លះនៃកម្មវិធីថ្វាយបង្គំ ដែលអ្នកនឹងផ្ទេរទៅអោយអ្នកផ្សេងៗដឹកនាំ ហើយសរសេរឈ្មោះអ្នកទាំងនោះក្បែរផ្នែកនោះ ។

© Project WorldReach © SEAN

ទីបន្ទាល់



តារាងខាងក្រោមនេះ បង្ហាញពីភាពខុសគ្នារវាងទំលាប់ល្អរបស់ពួកអ្នកដឹកនាំដែលបានរៀបចំល្អ និង កំហុសរបស់ពួកអ្នកដឹកនាំដែលមិនបានរៀបចំសព្វគ្រប់ពេញលេញ ។ នៅពេលដែល យើងរៀបចំ និង ដឹកនាំកម្មវិធីថ្វាយបង្គំ យើងត្រូវនឹកគិតអំពីចំណុចផ្សេងៗទាំងនេះ :

កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំបានរៀបចំល្អ	**កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំមិនសូវរៀបចំល្អ**
• ពួកអ្នកដឹកនាំអធិស្ឋានបានច្រើនដើម្បីរៀបចំការថ្វាយបង្គំ ។	• ពួកអ្នកដឹកនាំអធិស្ឋានបន្តិចបន្តួច ដើម្បីរៀបចំការថ្វាយបង្គំ ។
• ពួកអ្នកដឹកនាំរៀបចំរបៀបដំណើរការនៃកម្មវិធីថ្វាយបង្គំទុកជាមុន ស្របតាមប្រធានបទសំខាន់មួយ ដែលត្រូវបានជ្រើសរើស ដោយហ្មត់ចត់ ។	• ពួកអ្នកដឹកនាំមកដល់ដោយមិនបានរៀបចំអ្វីទាំងអស់ ។
• ពួកអ្នកដឹកនាំចេះរៀបចំផ្លាស់ប្តូរកម្មវិធី ។	• ពួកអ្នកដឹកនាំរៀបចំតែកម្មវិធីដដែលៗរហូត ។

កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំ បានរៀបចំល្អ	កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំមិនសូវរៀបចំល្អ
• ពួកអ្នកដឹកនាំ មកមុនពេលកម្មវិធីចាប់ផ្តើម ព្រោះពួកគេមានបំណងចង់យកឱកាស ដើម្បីប្រកបស្និទ្ធស្នាលជាមួយព្រះអង្គ និង រៀបចំចិត្តគំនិត ។	• ពួកអ្នកដឹកនាំមកដល់យឺតយ៉ាវ ព្រោះគេមិនសូវមានបំណងចង់យកឱកាស ដើម្បីរៀបចំចិត្តគំនិត និងធ្វើឱ្យខ្លួនចេះពឹងលើព្រះអង្គទេ ។
• ក្នុងកម្មវិធីថ្វាយបង្គំ ពួកអ្នកដឹកនាំចេះអញ្ជើញក្រុមជំនុំអោយឈរខ្លះ អង្គុយខ្លះ ទៅតាមកាលៈទេសៈ ។	• ក្នុងកម្មវិធីថ្វាយបង្គំ ពួកអ្នកដឹកនាំ អោយក្រុមជំនុំអង្គុយរហូត ។
• ពួកអ្នកដឹកនាំ នាំក្រុមជំនុំឱ្យច្រៀងបទសរសើរតម្កើងព្រះ-ជាម្ចាស់ និង ថ្វាយបង្គំព្រះអង្គ ដោយអស់ពីចិត្ត ។	• ពួកអ្នកដឹកនាំ នាំក្រុមជំនុំច្រៀងចំរៀងកុមារ និងបទថ្វាយបង្គំតែបន្តិច ។



កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំ បានរៀបចំល្អ	កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំមិនសូវរៀបចំល្អ
• ពួកអ្នកដឹកនាំហាត់អានបទព្រះគម្ពីរ មុនមកដល់ ដើម្បីអានឱ្យច្បាស់ជូនក្រុមជំនុំ ។	• ពួកអ្នកដឹកនាំ មិនសូវហាត់អានបទព្រះគម្ពីរ ដែលគេត្រូវអាន នៅក្នុងកម្មវិធី-ថ្វាយបង្គំ ដូច្នេះ គេអានមិនបានល្អ ។
• ពួកអ្នកដឹកនាំស្លៀកពាក់ស្អាត បាត និង មានទឹកមុខញញឹម ។	• ពួកអ្នកដឹកនាំ មិនបានស្លៀកពាក់សមរម្យ ហើយមិនសូវញញឹមទេ ។
• ពួកអ្នកដឹកនាំបានជ្រើសរើសយ៉ាងហ្មត់ចត់ ទុកជាមុននូវបទចំរៀង ដែលទាក់ទងនឹងប្រធានបទរបស់សេចក្តី-អធិប្បាយ និងដែលអាចនាំអោយពួកអ្នកជឿចូលទៅជិតព្រះជាម្ចាស់ ។	• ពួកអ្នកដឹកនាំតែងសួរគ្នាថា÷ «ឥឡូវនេះ តើយើងត្រូវច្រៀងបទអ្វី» ?

កំណាព្យ ការធ្វើសេចក្តីរាយការណ៍អំពីការងារ ការលេងរឿង ដែលដកស្រង់ពីព្រះគម្ពីរ ឬ ការសំដែងផ្សេងៗ ។

ជួនកាល មុនកម្មវិធីថ្វាយបង្គំ ឬ ក្នុងកម្មវិធីថ្វាយបង្គំ ឬ ក្រោយកម្មវិធីថ្វាយបង្គំ ទុកពេលសមល្មមអោយពួកអ្នកថ្វាយបង្គំ ដើម្បីអធិស្ឋានឱ្យគ្នាទៅវិញទៅមក និយាយគ្នា និងរៀបចំគំរោងការ ។ ពួកអ្នកថ្វាយបង្គំក៏ត្រូវបរិភោគអាហារជាមួយគ្នាយូរៗម្តងដែរ ។

សូមអោយក្មេងៗចូលរួមក្នុងកម្មវិធីថ្វាយបង្គំដែរ ។ ពួកកុមារអាចច្រៀង ឬធ្វើទីបន្ទាល់យូរៗម្តងបាន ។

កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំ បានរៀបចំល្អ	កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំមិនសូវរៀបចំល្អ
• ពួកអ្នកដឹកនាំ ដឹងពីពេលដែលខ្លួនត្រូវច្រៀង អាន ឬ និយាយ ។	• ពួកអ្នកដឹកនាំ ត្រូវខាតពេលវេលា ដោយសារត្រូវប្រកាសពីសកម្មភាពនិមួយៗ និងដោយសារពួកអ្នកដឹកនាំដែលមានតួនាទី ត្រូវត្រៀមខ្លួន ។ ភាពរញ៉ៃរញ៉ៃនេះ ធ្វើអោយអាក់ខានដល់ការហូរនៃការថ្វាយបង្គំ ។
• ពន្លឺភ្លើងមានគ្រប់គ្រាន់ ហើយដាក់ចំកន្លែង គឺដាក់ភ្លើងចំពីលើអ្នកថ្វាយបង្គំ ឬដាក់ភ្លើងខ្លះពីខាងក្រោយអ្នកថ្វាយបង្គំ ។	• ពន្លឺភ្លើងមិនគ្រប់គ្រាន់ ឬដាក់ចង្កៀងចំពីមុខ នាំអោយចាំងភ្នែកអ្នកថ្វាយបង្គំ ។

- អធិស្ឋានទូលអង្វរសំរាប់ក្រុមជំនុំ ប្រទេសជាតិ គ្រីស្តទូតនៅទឹកដីផ្សេង អ្នកឈឺ និងមនុស្សដែលមានការខ្វះខាត ។
- ធ្វើសេចក្តីប្រកាសអំពីដំណឹង ឬ កម្មវិធីផ្សេងៗ ។
- ថ្វាយបង្គំដោយដាក់ដង្វាយស្មគ្រចិត្ត និងដង្វាយដប់ភាគរយ ។
- ធ្វើពិធីកាច់នំប៉័ង ដោយប្រកបជាមួយព្រះអម្ចាស់ និងអ្នកថ្វាយបង្គំឯទៀត ។
- ថ្វាយខ្លួនចំពោះព្រះជាម្ចាស់ និងកិច្ចការបំរើព្រះអង្គតាមរយៈការច្រៀង ឬ ការអធិស្ឋាន ។
- បញ្ចប់ការថ្វាយបង្គំ ដោយអធិស្ឋានសូមអោយព្រះជាម្ចាស់ប្រទានព្រះពរដល់ក្រុមជំនុំ ។

អ្នកដឹកនាំក្រុមជំនុំត្រូវផ្តល់ឱកាសអោយសមាជិករបស់ក្រុមជំនុំជាពិសេស សមាជិកដែលនៅក្នុងក្រុមតូច អាចចូលរួមថ្វាយបង្គំទៅតាមចំណូលចិត្តរបស់ពួកគេ ដូចជាការច្រៀងសរសើរតម្កើង ការអធិស្ឋាន ការរំលឹកដាស់តឿន ការធ្វើទីបន្ទាល់ដែលបណ្តាលដោយព្រះវិញ្ញាណដ៏វិសុទ្ធ ការលេងបទភ្លេងពិសេស ការសូត្រ

អេភេសូ ១:៧-៨ ។ល។ ឬ ច្រៀងចំរៀងមួយអំពីការអត់ទោស) ។ សូមនឹកចាំថា ក្រុមជំនុំថ្មីៗភាគច្រើន មានអ្នកជឿមិនទាន់ឈានដល់កិរិតចាស់ទុំខាងព្រលឹងវិញ្ញាណច្រើន ដែលកំពុងតស៊ូប្រឆាំងនឹងអំពើបាប ។ ដូច្នេះ ពួកគេត្រូវស្គាល់អំពីការអត់ទោសរបស់ព្រះជាម្ចាស់ និងព្រះហឫទ័យប្រណីសណ្តោសរបស់ព្រះអង្គ ។

- ជីកនាំមនុស្សអោយថ្វាយបង្គំព្រះជាម្ចាស់ ដោយទំនុកតម្កើង បទចំរៀង និង ចំរៀងសរសើរតម្កើង ។
- អានវគ្គព្រះគម្ពីរមួយ ឬ ច្រើនវគ្គ (អានអោយល្អ) ។ ជួនកាលពួកគេអាចអានឆ្លាស់គ្នា (គឺអ្នកជីកនាំម្នាក់អានមួយខ ក្រុមជំនុំអានខបន្ទាប់) ។
- ច្រៀងចំរៀងសរសើរតម្កើង ដែលទាក់ទងនឹងប្រធានបទរបស់សេចក្តីអធិប្បាយ ។
- អធិប្បាយ ឬ បង្រៀនព្រះគម្ពីរ ឬ ពិចារណាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយរបៀបផ្សេងៗ (ដោយបកស្រាយព្រះគម្ពីរ ឬ សិក្សាព្រះគម្ពីរ ឬ សំដែងរឿងដែលដកស្រង់ចេញពីព្រះគម្ពីរ ឬ ថ្លែងព្រះបន្ទូលដែលព្រះអង្គបើកសំដែង) ។

កម្មវិធីថ្វាយបង្គំ ដែលអ្នកជីកនាំបានរៀបចំល្អ	**កម្មវិធីថ្វាយបង្គំ ដែលអ្នកជីកនាំមិនសូវរៀបចំល្អ**
• ក្មេងៗនៅស្ងៀមស្ងាត់ ហើយក្មេងៗទុកកៅអីអោយមនុស្សចាស់អង្គុយ បើសិនជាខ្វះកន្លែងអង្គុយ ។	• ក្មេងៗអង្គុយ នៅកន្លែងល្អៗ ហើយនិយាយឡូឡា ។
• ពួកអ្នកជីកនាំណែនាំអោយក្រុមជំនុំ ធ្វើពិធីកាច់នំប៉័ងដោយទឹកចិត្តបន្ទាបខ្លួន ។	• ពួកអ្នកជីកនាំ មិនសូវណែនាំក្រុមជំនុំអោយធ្វើពិធីកាច់នំប៉័ងទេ ឬក៏គេគ្រាន់តែធ្វើតាមទំលាប់ ដោយមិនស្វែងរកវត្តមានរបស់ព្រះគ្រីស្ត ។
• ពួកអ្នកជីកនាំផ្លាស់ប្តូរប្រធានបទនៃសេចក្តីអធិប្បាយយោងទៅតាមសេចក្តីត្រូវការរបស់ក្រុមជំនុំ ។	• មានគ្រូអធិប្បាយ តែម្នាក់ដែលអធិប្បាយគ្រប់ពេល ហើយអធិប្បាយ តែពីប្រធានបទដដែលៗ ។
• ទីកន្លែងប្រជុំមានអនាម័យ និងមានសណ្តាប់ធ្នាប់ ។	• ទីកន្លែងគ្មានសណ្តាប់ធ្នាប់ ។

កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំបានរៀបចំល្អ	កម្មវិធីថ្វាយបង្គំ ដែលអ្នកដឹកនាំមិនសូវរៀបចំល្អ
• សមាជិកចេះទទួលភ្ញៀវដោយរាក់ទាក់ ។ ពួកគេអញ្ជើញភ្ញៀវ ទៅរកកន្លែងល្អសំរាប់អង្គុយ ។ សមាជិកនិយាយរកភ្ញៀវ ដើម្បីអាចស្គាល់គ្នាទៅវិញទៅមក ។	• សមាជិកតិចណាស់ ដែលគិតគូរអំពីភ្ញៀវ ឬនិយាយរកភ្ញៀវ ។
• ពួកអ្នកដឹកនាំលើកទឹកចិត្ត បង្រួបបង្រួម និងកសាងសមាជិកក្នុងក្រុមជំនុំ ។	• ពួកអ្នកដឹកនាំ ស្តីបន្ទោសសមាជិកក្នុងក្រុមជំនុំ ។
• សមាជិកក្រុមជំនុំរាក់ទាក់គ្នាហើយនិងនិយាយជាមួយភ្ញៀវមុន និងក្រោយកម្មវិធីថ្វាយបង្គំ ។	• ពេលចប់កម្មវិធីថ្វាយបង្គំ សមាជិកក្រុមជំនុំចេញទៅដោយគ្មាននិយាយរកគ្នា ។

ផ្នែកសំខាន់ៗនៃកម្មវិធីថ្វាយបង្គំ

(គំរូមួយអំពីកម្មវិធីថ្វាយបង្គំ)

ត្រូវផ្លាស់ប្តូររបៀបថ្វាយបង្គំយូរៗម្តង ដើម្បីកុំឱ្យកម្មវិធីនេះក្លាយជាទំលាប់ដដែលៗ ។ ពួកអ្នកដឹកនាំត្រូវទុកអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំគេនៅក្នុងការថ្វាយបង្គំ ។ ការថ្វាយបង្គំជាការជួបជាមួយព្រះជាម្ចាស់ ដែលមនុស្សមិនអាចធ្វើអោយកើតមានដោយខ្លួនឯងបានទេ ។ កម្មវិធីថ្វាយបង្គំល្អ មានចំណុចដូចមានរៀបរាប់ខាងក្រោមនេះភាគច្រើន :

- អធិស្ឋានអំពាវនាវរកព្រះជាម្ចាស់ និងអរព្រះគុណចំពោះវត្តមានរបស់ព្រះអង្គ (ដែលព្រះអង្គគង់ជាមួយយើង) ។
- លន់តួសារភាពអំពើបាបរបស់យើង (ដោយការអធិស្ឋានជាមួយគ្នា ឬ អធិស្ឋានក្នុងចិត្ត ឬក៏ច្រៀងចំរៀងមួយអំពីការលន់តួបាប) ។
- អះអាងថា ព្រះជាម្ចាស់បានលើកលែងទោសអោយយើងហើយ គឺថាពេលដែលយើងកែប្រែចិត្តគំនិត យើងបានទទួលការអត់ទោសតាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ត (ដោយអានវគ្គព្រះគម្ពីរ ដូចជា ១ យ៉ូហាន ១:៩ ឬ